ថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា
**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៧១ អនក្រ.បក**

**ស្តីពី**

**ការបង្កើតគណៈកម្មការជាតិ សំរាប់បង្ការទប់ស្កាត់**
**និង បន្ថយជំងឺអេដស៍ និង ជំងឺកាមរោគ**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាកសត្រ នៃព្រះរាជាណាចក្រកមសុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សំរេច

**មាត្រា ១** : បង្កើតគណៈកម្មការជាតិមួយឈ្មោះថា គណៈកម្មការជាតិសំរាប់បង្ការទប់ស្កាត់ និងបន្ថយជំងឺអេដស៍ និងជំងឺកាមរោគ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១– សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ | ប្រធានកិត្តិយស |
| ២– ឯកឧត្តម **ឈា ថាំង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ប្រធាន |
| ៣– ឯកឧត្តម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤– ឯកឧត្តម រដ្ឋលេខាធិការក្រសួងពត៌មាន | សមាជិក |
| ៥– ឯកឧត្តម រដ្ឋលេខាធិការក្រសួងអប់រំ | សមាជិក |
| ៦– ឯកឧត្តម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី | សមាជិក |
| ៧– ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៨– លោក អភិបាលរងរាជធានីភ្នំពេញ និង ខេត្ត ក្រុង | សមាជិក |

**មាត្រា ២** : គណៈកម្មការជាតិ សំរាប់បង្ការទប់ស្កាត់ និងបន្ថយជំងឺអេដស៍ និងជំងឺកាមរោគមានលេខាធិការដ្ឋានជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១– លោក វេជ្ជបណ្ឌិត **ហ៊ុន ឈុនលី** | ប្រធានលេខាធិការដ្ឋាន |
| ២– លោក តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣– លោក តំណាងក្រសួងអប់រំ | សមាជិក |
| ៤– លោក តំណាងក្រសួងពត៌មាន | សមាជិក |
| ៥– លោក តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ៦– លោកស្រី តំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការនារី | សមាជិក |
| ៧– លោកវេជ្ជបណ្ឌិត **ហោ ម៉ុនឡេង** មន្ត្រីក្រសួងសុខា ភិបាល | សមាជិក |

**មាត្រា ៣** :គណៈកម្មការជាតិ សំរាប់បង្ការទប់ស្កាត់ និងបន្ថយជំងឺអេដស៍ និងជំងឺកាមរោគមានភារកិច្ច :

- ទទួលខុសត្រូវរួមលើវិធានការការពារ និងព្យាបាល ទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ និងជំងឺកាមរោគ ។
- ទទួលខុសត្រូវពិនិត្យស្រាវជ្រាវជំងឺអេដស៍ ជំងឺកាមរោគ និងធ្វើស្ថិតិមេបនពេស្យា

និងស្ត្រីពេស្យា ក្នុងព្រះរាជាណាចក្រកម្ពុជា ។

- លើកយោបល់ជូនរាជរដ្ឋាភិបាលកម្ពុជាអំពីបញ្ហាទាំងឡាយដែលទាក់ទង និងសភាព-ការណ៍ជំងឺអេដស៍ ជំងឺកាមរោគ ពេស្យាចារ និងមេបនពេស្យា ។
- ផ្តល់យោបល់ណែនាំដល់មន្ទីរពិសោធន៍ និងមន្ទីរពេទ្យដែលទទួលព្យាបាល ថែទាំអ្នកផ្ទុកមេរោគ អេច-អៃ-វី ឬអ្នកកើតជំងឺអេដស៍ និងអ្នកកើតជំងឺកាមរោគ ។
- ទទួលខុសត្រូវរៀបចំច្បាប់ និងលិខិតបទដ្ឋានស្តីពីការបង្ការ ទប់ស្កាត់ និង បន្ថយជំងឺអេដស៍ និងសកម្មភាពពេស្យាចារ ។
- ពិនិត្យ អនុម័ត លើគំរោងកម្មវិធីអប់រំ ដែលត្រូវធ្វើការផ្សព្វផ្សាយ នៅតាមសាលារៀន តាមក្រសួងស្ថាប័ននានា តាមវិទ្យុ និងទូរទស្សន៍ និង លើកម្មវិធីអប់រំស្ត្រីពេស្យាដោយផ្ទាល់ ។
- ជំរុញការអនុវត្តន៍នូវបណ្តាវិធានការទាំងឡាយដែលរាជរដ្ឋាភិបាលបានដាក់ចុះ ។

លេខាធិការដ្ឋានមានភារកិច្ច :

- ផ្តល់ពត៌មានអំពីសកម្មភាពនៃការអនុវត្តន៍ការងារបង្ការ ទប់ស្កាត់ និងបន្ថយជំងឺអេដស៍ និង ជំងឺកាមរោគតាមកាលកំណត់ជូនគណៈកម្មការជាតិនេះ ។
- រៀបចំខ្លឹមសារ រូបភាពសំរាប់ផ្សព្វផ្សាយតាមវិទ្យុ-ទូរទស្សន៍ អោយបានទៀងទាត់ និងសមស្របតាមប្រពៃណីជាតិ ជៀសវាងរូបអាសអាភាស ។
- រៀបចំខ្លឹមសារ និងរូបភាពសំរាប់បញ្ចូលក្នុងកម្មវិធីសិក្សានានា និង សំរាប់ផ្សព្វផ្សាយតាមក្រសួងស្ថាប័ន អោយស្របតាមប្រពៃណីជាតិ ។ ចំពោះបនពេស្យាត្រូវអនុវត្តដោយឡែក ។
- ទទួលខុសត្រូវក្នុងការតាមដាន និងអនុវត្តនូវសកម្មភាពទាំងឡាយក្នុងកម្មវិធីបង្ការ ទប់ស្កាត់ និងបន្ថយជំងឺអេដស៍ និង ជំងឺកាមរោគ តាមដំណាក់កាលនីមួយ ៗ ។
- សហការជាមួយក្រសួងមានសមត្ថកិច្ចក្នុងការបង្ក្រាបមេបន និងអប់រំពេស្យាចារ ។
- លើកកម្មវិធីរយៈពេលខ្លី មធ្យម វែង ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ និងជំងឺកាមរោគ និងលើកគំរោងថវិកាសំរាប់ចំណាយក្នុងការងារនេះ ។
- សហការយ៉ាងជិតស្និទ្ធជាមួយអង្គការសុខភាពពិភពលោក និងអង្គការអន្តរជាតិនានា

ដើម្បីទាក់ទងសុំជំនួយឧបត្ថម្ភថវិកា ឧបករណ៍ សំភារៈ សំរាប់បំរើការងារនេះអោយដំណើរការបានជាប់ជាប្រចាំ ។

- ធ្វើរបាយការណ៍អោយបានទៀងទាត់រៀងរាល់ដំណាច់ខែជូនរាជរដ្ឋាភិបាល ស្តីពីសភាពការណ៍វិវឌ្ឍន៍ និងការរីកចំរើននៃសកម្មភាពរបស់គណៈកម្មការជាតិនេះ ។

**មាត្រា ៤** : គណៈកម្មការជាតិ សំរាប់បង្ការទប់ស្កាត់ និងបន្ថយជំងឺ អេដស៍ និងជំងឺកាមរោគ មានទីស្នាក់ការអចិន្ត្រៃយ៍នៅក្រសួងសុខាភិបាល និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល ។

**មាត្រា ៥** : សេចក្តីសំរេចលេខ ៣៦ សសរ ចុះថ្ងៃទី ១១-១២-៩៣ និង បទបញ្ញត្តិទាំងឡាយដែលផ្ទុយពីខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការដ្ឋានកិច្ចការនារី ក្រសួងទេសចរណ៍ ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ អភិបាល ខេត្ត-ក្រុង និងឯកឧត្តម អស់លោក លោកស្រី ដែលមានចែងក្នុងមាត្រា ១ ២ និង ៦ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៧២ អនក្រ.បក**

**ស្តីពី**

**ការកែសំរួលនាយកដ្ឋានធារាសាស្ត្រ ឧតុនិយមនិងជលសាស្ត្រ**

**ឱ្យទៅជា អគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយមនិងជលសាស្ត្រ**